# មាតិកា

## I~ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ

០១-៣-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០៣០៦/១០០ ស្តីពីការផ្តល់សញ្ជាតិខ្មែរតាមសញ្ជាតូបនីយកម្ម ដល់កញ្ញា **វូ ធីតាន់** (VU THI TAN) ជនជាតិវៀតណាម សញ្ជាតិវៀតណាម កើតនៅខេត្តក្វាងនីញ ប្រទេសវៀតណាម ដោយប្តូរឈ្មោះជា **វូ សុភា** (VU SOPHEA) ១៥៣៥

## II~ក្រុមប្រឹក្សាធម្មនុញ្ញ

១៧-៣-២០០៦ -សេចក្តីសំរេចលេខ ០៧៤/០០១/២០០៦ កបធ.ច ចុះថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០០៦ ១៥៣៦

## III~រាជរដ្ឋាភិបាល

### ១~អនុក្រឹត្យ

១៦-៣-២០០៦ -អនុក្រឹត្យលេខ ១៧២ អនក្រ.តត ស្តីពីការផ្ទេរក្របខ័ណ្ឌមន្ត្រីក្រមការក្រសួងមហាផ្ទៃ ១៥៣៨

១៦-៣-២០០៦ -អនុក្រឹត្យលេខ ១៧៣ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ១៥៣៩

១៦-៣-២០០៦ -អនុក្រឹត្យលេខ ១៧៤ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ១៥៤០

### ២~សេចក្តីសំរេច

១៦-៣-២០០៦ -សេចក្តីសំរេចលេខ ០៧ សសរ ស្តីពីការបង្កើតគណៈកម្មការសម្របសម្រួលការងាររៀបចំប្រព័ន្ធទិដ្ឋាការអេឡិចត្រូនិច "E-visa" ១៥៤១

## IV~ការងារបណ្តាក្រសួង

### ១~ទីស្តីការរដ្ឋមន្ត្រី ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ

១៥-៣-២០០៦ -ប្រកាសលេខ ០៥២ ក.ក.ប.វ/ប្រក ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្ត-ក្រុង ១៥៤៣

### ២~ទីស្តីការរដ្ឋមន្ត្រី ក្រសួងការពារជាតិ

១៧-៣-២០០៦ -ប្រកាសលេខ ០១២ ប្រក/២០០៦ ស្តីពីការបង្កើតក្រុមប្រឹក្សាកីឡាកងយោធពលខេមរភូមិន្ទ ១៥៥១

## ៣-ទីស្តីការរដ្ឋមន្ត្រី ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់


០៦-០២-២០០៦ -សេចក្តីសំរេចលេខ ០៥ សសរ ស្តីពីការកំណត់បរិបថនៃការពិនិត្យ និងសំរេចលើពាក្យសុំលិខិតអនុញ្ញាតសាងសង់ ១៥៥៤


## ៣-ទីស្តីការរដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម


០៣-០១-២០០៦ -លិខិតលេខ ០៣១ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ជី អិម អ៊ី** ១៥៨៣

០៣-០១-២០០៦ -លិខិតលេខ ០៣៤ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **លី មុន សៀវ គ្រុប** ១៥៨៥

០៣-០១-២០០៦ -លិខិតលេខ ០៣៥ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ខេ.អេស.ខេ.ដាប់បែលយូ (ខេមបូឌា)** ១៥៨៧

០៣-០១-២០០៦ -លិខិតលេខ ០៥១ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ធី អិន ធី អិចប្រេស វើលវ៉ាយដ៍ (ខេមបូឌា) អិលធីឌី** ១៥៨៩

០៤-០១-២០០៦ -លិខិតលេខ ០៥៥ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **តាំង ថៃ ឡុង** ១៥៩១

០៤-០១-២០០៦ -លិខិតលេខ ០៥៦ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **សុខសប្បាយ ស៊ូភើ-ស្តរ ខបភើរេសិន** ១៥៩៣

០៤-០១-២០០៦ -លិខិតលេខ ០៥៧ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ខេម កេន អ៊ិនធើណេសិនណល អ៊ិនវេសមេន** ១៥៩៥

០៤-០១-២០០៦ -លិខិតលេខ ០៥៨ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **សូឡារីស (ខេមបូឌា)** ១៥៩៧

០៤-០១-២០០៦ -លិខិតលេខ ០៥៩ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **អ.គី.អេច គ្រុប** ១៥៩៩

០៤-០១-២០០៦ -លិខិតលេខ ០៦០ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **តេខ តុខ ស្ពារ អេឡិចត្រូនិក ខូ អិលធីឌី** ១៦០១

០៤-០១-២០០៦ -លិខិតលេខ ០៦២ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ហ្គាស ខា (ខេមបូឌា)** ១៦០៣

០៤-០១-២០០៦ -លិខិតលេខ ០៦៣ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ហ្គោលដេន មេ ឌីវេឡុបមេន ខូ អិលធីឌី** ១៦០៥

០៤-០១-២០០៦ -លិខិតលេខ ០៦៤ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ឈុន រតនៈ** ១៦០៧

០៤-០១-២០០៦ -លិខិតលេខ ០៦៧ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ជេនិស៊ីស (ខេមបូឌា)** ១៦០៩

០៤-០១-២០០៦ -លិខិតលេខ ០៦៨ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **អាយ អិន អេស_ភី ជី (ខេមបូឌា)** ១៦១១

០៤-០១-២០០៦ -លិខិតលេខ ០៦៩ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **យូហ្សេត្ររាយ/ឌីអិនអេ អេនើជី (ខេមបូឌា)** ១៦១៣

០៤-០១-២០០៦ -លិខិតលេខ ០៧០ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **មេហ្គា តែកឃីជីខ** ១៦១៥

០៤-០១-២០០៦ -លិខិតលេខ ០៧៤ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **សម្បត្តិ អេនើចាញ ខបតើរេសិន** ១៦១៧

០៤-០១-២០០៦ -លិខិតលេខ ០៦០ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ទេច តុង ស្ពារ អេឡិច ត្រូនិក ខូ អិលធីឌី** ១៦០១

០៤-០១-២០០៦ -លិខិតលេខ ០៦២ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ហ្គ្លាស ខា (ខេមបូឌា)** ១៦០៣

០៤-០១-២០០៦ -លិខិតលេខ ០៦៣ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ហ្គោលដេន បេ ឌីវេឡុបមេន ខូ អិលធីឌី** ១៦០៥

០៤-០១-២០០៦ -លិខិតលេខ ០៦៤ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ឈុន រតនៈ** ១៦០៧

០៤-០១-២០០៦ -លិខិតលេខ ០៦៧ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ជេនិស៊ីស (ខេមបូឌា)** ១៦០៩

០៤-០១-២០០៦ -លិខិតលេខ ០៦៨ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **អាយ អិន អេស_ភី ជី (ខេមបូឌា)** ១៦១១

០៤-០១-២០០៦ -លិខិតលេខ ០៦៩ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **យូហ្សេរអាយ/ឌីអិនអេ អេនើជី (ខេមបូឌា)** ១៦១៣

០៤-០១-២០០៦ -លិខិតលេខ ០៧០ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **មេហ្គា តែកឃីដឹង** ១៦១៥

០៤-០១-២០០៦ -លិខិតលេខ ០៧៤ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **សម្បត្តិ អេនើចាញ ខបភើរេសិន** ១៦១៧

# ព្រះរាជក្រឹត្យ

នស/រកត/០៣០៦/១០០

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរិវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១ :** ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់កញ្ញា **វូ ធីតាន់** (VU THI TAN) ជនជាតិវៀតណាម សញ្ជាតិវៀតណាម កើតថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ១៩៨៤ នៅខេត្តក្វាងនីញ (QUANG NINH) ប្រទេសវៀតណាម ដោយប្តូរឈ្មោះជា **វូ សុភា** (VU SOPHEA) ។

**មាត្រា ២ :** សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

លេខ: ១០៨ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី០៦ ខែមីនា ឆ្នាំ២០០៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឈាង តាន់**

៣៧ល.០៧០៣.១០៥

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១ ខែ មីនា ឆ្នាំ ២០០៦

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**
លេខ : ១០២/០០២/២០០៦
ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០៦
**សេចក្តីសម្រេច**
លេខ : ០៧៤/០០១/២០០៦ កបធ.ច
ចុះថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០០៦

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៦/០០៦ ចុះថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ២០០៦ ប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ៨២ មាត្រា ៨៨ថ្មី មាត្រា ៩០ថ្មី មាត្រា ៩៨ មាត្រា ១០៦ថ្មី មាត្រា ១១១ថ្មី (មួយ) មាត្រា ១១៤ថ្មី នៃរដ្ឋធម្មនុញ្ញ និងមាត្រា ៦ នៃច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញលិខិតលេខ ២០/២០០៣ កបធ ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០០៣ របស់ក្រុមប្រឹក្សាធម្មនុញ្ញ ដែលទូលថ្វាយយោបល់ចំពោះព្រះមហាក្សត្រអំពីចំណុចផ្នែកច្បាប់មួយចំនួន ពិសេសអំពីព្រះរាជតំណាង ដែលមានចែងក្នុងប្រការ ៥ថ្មី(ពីរ) នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញលិខិតលេខ ២៧៤ រស ចុះថ្ងៃទី ១៥ ខែ មីនា ឆ្នាំ២០០៦ របស់សម្តេច **ហេង សំរិន** អនុប្រធានទី១ រដ្ឋសភា ស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពលើវិសោធនកម្មប្រការ ២ ថ្មី ៥ ថ្មី ១០ ថ្មី ៣៥ ៤៧ ថ្មី(ពីរ) និង ប្រការ ៨២ នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលនៅថ្ងៃទី ១៥ ខែមីនា ឆ្នាំ២០០៦ វេលាម៉ោង ១០:៣១ នាទី។

**ក្រោយពីបានស្តាប់សេចក្តីរាយការណ៍របស់សមាជិករាយការណ៍**
**ក្រោយពីបានពិភាក្សាគ្រប់គ្រាន់តាមច្បាប់ហើយ**

- យល់ឃើញថា មាត្រា ១៤០ថ្មី នៃរដ្ឋធម្មនុញ្ញ ឆ្នាំ ១៩៩៣ ត្រង់កថាខណ្ឌទី២ ឃ្លាទី ១ ចែងថា *" បទបញ្ជាផ្ទៃក្នុងរដ្ឋសភា បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា និង ច្បាប់រៀបចំអង្គការទាំងឡាយ ត្រូវតែបញ្ជូនទៅក្រុមប្រឹក្សាធម្មនុញ្ញ*

*ពិនិត្យមុននឹងប្រកាសឱ្យប្រើ ។*" និងមាត្រា ១៦ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ បានចែងថា " *ច្បាប់រៀបចំអង្គការ បទបញ្ជាផ្ទៃក្នុងរដ្ឋសភា និង វិសោធនកម្មនៃច្បាប់រៀបចំអង្គការ និង បទបញ្ជាផ្ទៃក្នុងរដ្ឋសភា ក្រោយពីរដ្ឋសភាបានអនុម័តត្រូវដាក់ជូនក្រុមប្រឹក្សាធម្មនុញ្ញ ដោយប្រធានរដ្ឋសភា ដើម្បីពិនិត្យតើច្បាប់ទាំងនោះស្រប ឬ មិនស្របនឹងរដ្ឋធម្មនុញ្ញ មុននឹងត្រូវបានប្រកាសឱ្យប្រើ* " ។

សំណើរបស់សម្តេច **ហេង សំរិន** អនុប្រធានទី១ រដ្ឋសភា លេខ ២៧៤ រស ចុះថ្ងៃទី ១៥ ខែ មីនា ឆ្នាំ២០០៦ ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលនៅថ្ងៃទី ១៥ ខែ មីនា ឆ្នាំ២០០៦ វេលាម៉ោង ១០:៣១ នាទី គឺស្របតាមរដ្ឋធម្មនុញ្ញ និង ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ។ ក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលយកសំណើសុំពិនិត្យធម្មនុញ្ញភាពនេះមកពិនិត្យបាន ។

- យល់ឃើញថា វិសោធនកម្មនៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា ដែលបានអនុម័តនៅថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី៤ នីតិកាលទី៣ត្រង់ប្រការ ២ថ្មី ៥ថ្មី ១០ថ្មី ៣៥ ៤៧ ថ្មី ( ពីរ ) និង ប្រការ ៨២ ពុំមានលក្ខណៈផ្ទុយនឹងរដ្ឋធម្មនុញ្ញទេ ។

## សម្រេច

**មាត្រា១.**_ វិសោធនកម្មប្រការ ២ ថ្មី ៥ ថ្មី ១០ ថ្មី ៣៥ ៤៧ ថ្មី(ពីរ) និងប្រការ ៨២ នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា ដែលបានអនុម័តនៅថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០០៦ នាសម័យប្រជុំរដ្ឋសភា លើកទី៤ នីតិកាលទី៣ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ ។

**មាត្រា២.**_ សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ១៧ ខែ មីនា ឆ្នាំ២០០៦ នាសម័យប្រជុំពេញអង្គនៃ ក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ២០០៦

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

ប៊ិន ឈិន

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ...១៣៧...អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពី

## ផ្ទេរក្របខ័ណ្ឌមន្ត្រីក្រមការក្រសួងមហាផ្ទៃ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០០/០៧៥ ចុះថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីក្រមការក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

## ស ម្រេ ច

**មាត្រា ១ .-** ត្រូវបានផ្ទេរក្របខ័ណ្ឌ លោកស្រី អ៊ុង គីរម្យ នាយក្រមការ ថ្នាក់លេខ ២ នៃក្របខ័ណ្ឌមន្ត្រីក្រមការក្រសួងមហាផ្ទៃ ជានាយក្រមការ ថ្នាក់លេខ ២ នៃក្របខ័ណ្ឌមន្ត្រីក្រមការ នៅក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ។

**មាត្រា ២ .-** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភានិងអធិការកិច្ច រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

**កន្លែងទទួល :**

- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា "៣"*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ:** ១៧៣ អនក្រ.តត

# អនុក្រឹត្យ
# ស្តីពី
# ការតែងតាំងមន្ត្រីរាជការ

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៥ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ៥២ អនក្រ.បក ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក. ចុះថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០០៦ ស្តីពីការបង្កើតមជ្ឈមណ្ឌលអភិវឌ្ឍន៍សហគ្រិនកម្ពុជា-ឥណ្ឌា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

**ស ម្រេ ច**

**មាត្រា ១ :** ត្រូវបានតែងតាំងលោក **ម៉ាន់ ណារ៉ា** ជានាយកមជ្ឈមណ្ឌលអភិវឌ្ឍន៍សហគ្រិនកម្ពុជា-ឥណ្ឌា នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានឋានៈស្មើប្រធាននាយកដ្ឋាន ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៦*

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល:**
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *ឯកសារ-កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
លេខៈ ១៧៤ អនក្រ.តត

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយសហមេត្រី

៙

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០៦ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស

## សម្រេច

**មាត្រា១៖** ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **សេនា** ជូនសមាជិក អង្គការវិស្វកម្ម អន្តរជាតិ ចំនួន ០៦រូប ដែលមានស្នាដៃល្អក្នុងកិច្ចសហប្រតិបត្តិការលើការងារវិស្វកម្ម រវាងសមាគមស្ថាប័នវិស្វកម្មកម្ពុជា និងអង្គការវិស្វកម្មអន្តរជាតិ កន្លងមក ដូចមានរាយនាមខាងក្រោមនេះ :-

| | |
|---|---|
| ១-Mr.Shinya YOSHITAKE | Former Vice President of IPEJ |
| ២-PhD. Nafis AHMED | Consultant of UNESCO Office, Jakarta |
| ៣-Mr.David SALTER | Manager of DFID/SEACAP |
| ៤-Dr. Supote S. PRASERTSRI | Chief Education Program, UNESCO Phnom Penh |
| ៥-Prof. Dr. Nguyen Truong Tien | *Member of VUSTA* |
| ៦-Er. Lee Bee WAH | *Past Vice President of IES* |

**មាត្រា២៖** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ ៣ ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ០២៧ អនក្រ

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតគណៈកម្មការសម្របសម្រួលការងាររៀបចំប្រព័ន្ធទិដ្ឋាការអេឡិចត្រូនិច "E-visa"

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

## ស ម្រេ ច

**ប្រការ១ :** បង្កើតគណៈកម្មការសម្របសម្រួលការងាររៀបចំប្រព័ន្ធទិដ្ឋាការអេឡិចត្រូនិច "E-visa" ដែលមានសមាសភាព ដូចខាងក្រោម:

| | | |
|---|---|---|
| ១- ឯកឧត្តម **ឡុង វិសាលោ** | រដ្ឋលេខាធិការ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | ប្រធាន |
| ២- លោកវរសេនីយ៍ឯក **ពុំ ទិត្យា** | អនុប្រធាននាយកដ្ឋានអន្តោប្រវេសន៍ ក្រសួងមហាផ្ទៃ | អនុប្រធាន |

៣-ឯកឧត្តម **ហង់ ជួនណារ៉ុន** អគ្គលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

៤-លោក **ខួន តាំងលាង** អគ្គលេខាធិការរង អាជ្ញាធរជាតិទទួលបន្ទុក អភិវឌ្ឍន៍បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានវិទ្យា ទីស្តីការគណៈរដ្ឋមន្ត្រី។ សមាជិក

**ប្រការ២** : គណៈកម្មការនេះមានតួនាទី និងភារកិច្ចដូចខាងក្រោម :

១-សម្របសម្រួលការងាររៀបចំហេដ្ឋារចនាសម្ព័ន្ធ និងការអភិវឌ្ឍប្រព័ន្ធ E-visa

២-ត្រួតពិនិត្យ និងសម្របសម្រួលក្នុងការគ្រប់គ្រងបញ្ជីខ្មៅឱ្យមានប្រសិទ្ធភាព ដោយភ្ជាប់ប្រព័ន្ធ E-visa ជាមួយប្រព័ន្ធព័ត៌មានអន្តរជាតិ ស្តីពីភេរវកម្មអន្តរជាតិ

៣-ត្រួតពិនិត្យដំណើរការអនុវត្តប្រព័ន្ធ E-visa និងតាមដានការគ្រប់គ្រងចំណូលពីប្រព័ន្ធ E-visa នេះ

៤-សម្របសម្រួល និងដោះស្រាយបញ្ហាបច្ចេកទេសក្នុងការគ្រប់គ្រង និងដំណើរការប្រព័ន្ធ E-visa និងបញ្ហាអសកម្មផ្សេងៗទៀត។

**ប្រការ៣** : គណៈកម្មការនេះមានសិទ្ធិអញ្ជើញថ្នាក់ដឹកនាំ តំណាងក្រសួង-ស្ថាប័នផ្សេងទៀត ដែលមិនស្ថិតក្នុងសមាជិកគណៈកម្មការដើម្បីចូលរួមប្រជុំពិភាក្សា និងសហការបំពេញការងារតាមការជាក់ស្តែង។

**ប្រការ៤** : សមាជិកទាំងអស់នៃគណៈកម្មការនេះត្រូវអញ្ជើញចូលរួមប្រជុំ និងធ្វើការងារតាមសេចក្តីអញ្ជើញ និងការណែនាំរបស់ប្រធាន។

**ប្រការ៥** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដែលមានចែងក្នុងប្រការមួយ ត្រូវអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

*កន្លែងទទួល :*

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចចែងក្នុងប្រការ ៥*
- *ឯកសារ-កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ**

លេខៈ ០៥២ ក.ក.ប.វ/ប្រ.ក

## ប្រកាស
## ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់
## មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្ត-ក្រុង

## រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រម ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី ១៣ ខែ មិនា ឆ្នាំ ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ-បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ៥២ អនក្រ-បក ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួង ។

## <u>សម្រេច</u>

**ប្រការ ១ :** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្ត ក្រុង ជាអង្គភាពមូលដ្ឋានរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានតួនាទីដឹកនាំគ្រប់គ្រងរដ្ឋបាល វិស័យការងារ វិស័យបណ្តុះបណ្តាល និងសម្របសម្រួលសកម្មភាពនានារបស់ក្រសួង ដោយអនុលោមតាមច្បាប់ និងបទបញ្ញាជាធរមាន។

**ប្រការ ២ :** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្ត ក្រុង មានភារកិច្ចដូចតទៅ :

### ក- កិច្ចការគ្រប់គ្រងរដ្ឋបាល

- គ្រប់គ្រង និងដឹកនាំរាល់សកម្មភាពការងាររបស់ការិយាល័យ មជ្ឈមណ្ឌល សាលាបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រោមឱវាទឱ្យមានប្រសិទ្ធភាពដោយកំណត់នូវតួនាទី និងបែងចែកភារកិច្ចទទួលខុសត្រូវ នៅផ្នែកនីមួយៗ

- ទទួលខុសត្រូវដោយផ្ទាល់ចំពោះក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ លើបញ្ហាដែលពាក់ព័ន្ធទៅនឹងការងាររដ្ឋបាល ការងារគ្រប់គ្រងហិរញ្ញវត្ថុ និងការងារបច្ចេកទេសរបស់ក្រសួង
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស ប្រចាំឆ្នាំ ដោយផ្អែកលើផែនការ និងណែនាំ របស់ក្រសួង
- រៀបចំគម្រោងចំណូល ចំណាយថវិកា ដែលពាក់ព័ន្ធការងារ និងមុខសញ្ញាដែលមន្ទីរគ្រប់គ្រង
- រៀបចំកសាងផែនការ រយៈពេលខ្លី មធ្យម និងវែងសំរាប់ការអភិវឌ្ឍន៍កម្មវិធី គម្រោងកម្មវិធី និងសកម្មភាពនានា ដែលស្ថិតនៅក្រោមការទទួលខុសត្រូវរបស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្ត ក្រុង ជូនក្រសួង
- ផ្សព្វផ្សាយគោលនយោបាយ របស់ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ ដល់គ្រប់ផ្នែកចំណុះ មន្ទីរ អង្គភាពមូលដ្ឋានចំណុះ ខេត្ត ក្រុង ភ្នាក់ងារជាតិ អន្តរជាតិ និងក្រុមសហគមន៍
- បង្កលក្ខណៈងាយស្រួល និង ផ្តល់ឱកាសឱ្យមន្ត្រីរាជការក្រោមឱវាទ ទទួលការបណ្តុះបណ្តាលមុខជំនាញ ចំណេះដឹង និងសមត្ថភាពជំនាញក្នុងការបំពេញមុខងារ ដោយសហការជាមួយការិយាល័យ អភិវឌ្ឍន៍ធនធានមនុស្សរបស់នាយកដ្ឋានរដ្ឋបាល និងបុគ្គលិក នៃអគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ និងនាយកដ្ឋានជំនាញផ្សេងៗទៀតរបស់ក្រសួង
- ពង្រឹងប្រព័ន្ធគ្រប់គ្រង និងបែបបទអនុវត្តការងារ ដោយធ្វើការតាមដាន ត្រួតពិនិត្យ វាយតម្លៃការងារបណ្តាញរដ្ឋបាល នៃមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឱ្យមានលក្ខណៈត្រឹមត្រូវ និង មានប្រសិទ្ធភាព
- តាមដានត្រួតពិនិត្យ និងវាយតម្លៃកម្មវិធី សកម្មភាពនានារបស់អង្គការផ្តល់ជំនួយជាតិ និងអន្តរជាតិដែលបានចុះកិច្ចព្រមព្រៀង ពិធីសារ ជាមួយក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ ហើយកំពុងធ្វើសកម្មភាពនៅតាម ខេត្ត ក្រុង
- ទទួលខុសត្រូវក្នុងការវាយតម្លៃ ស្នើតម្លើងថ្នាក់ ឋានន្តរស័ក្តិ ដាក់ឱ្យចូលនិវត្តន៍ បញ្ឈប់ការងារ ដល់មន្ត្រីរាជការក្រោមឱវាទ តាមគោលការណ៍ណែនាំរបស់ក្រសួង
- រៀបចំ និងគ្រប់គ្រងបញ្ជីសារពើភ័ណ្ឌ សម្ភារៈ បរិក្ខារ ចលនទ្រព្យ អចលនទ្រព្យ ដែលស្ថិតនៅក្រោមសមត្ថកិច្ចគ្រប់គ្រងរបស់មន្ទីរ
- សហការជាមួយអាជ្ញាធរមូលដ្ឋាន ខេត្ត ក្រុង លើរាល់កិច្ចការដែលពាក់ព័ន្ធនឹងភារកិច្ចរបស់ក្រសួង និងកិច្ចការចាំបាច់របស់ ខេត្ត ក្រុង
- តាមដានត្រួតពិនិត្យ វាយតម្លៃ និងធ្វើរបាយការណ៍លទ្ធផលអនុវត្តកម្មវិធីគម្រោងកម្មវិធី ដែលពាក់ព័ន្ធទៅនឹងការទទួលខុសត្រូវរបស់មន្ទីរ ។

## ខ_ ទិសំយការងារ

- ត្រួតពិនិត្យការអនុវត្តន៍ច្បាប់ស្តីពីការងារ លិខិតបទដ្ឋានរបស់ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ នៅតាមសហគ្រាស គ្រឹះស្ថាន ដែលស្ថិតនៅក្នុង ខេត្ត ក្រុង

- ទទួលខុសត្រូវការងារមុខរបរ និងបាត្តពលកម្ម ដោយគ្រប់គ្រងស្ថិតិមុខរបរ ស្ថិតិអ្នកគ្មានការងារធ្វើ
- ជួយសម្របសម្រួលរកការងារធ្វើ ជូនប្រជាពលរដ្ឋដែលស្វែងរកការងារធ្វើ ដោយទទួលពាក្យសុំការងារធ្វើ និងចេញប័ណ្ណរកការងារធ្វើជូនអ្នកដាក់ពាក្យសុំការងារធ្វើគ្រប់ប្រភេទតាមល័ក្ខការណ៍កំណត់របស់ក្រសួង ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- រៀបចំសំណុំលិខិតធ្វើប័ណ្ណ និងសៀវភៅការងារកម្មករនិយោជិតខ្មែរ
- ទទួល និងរៀបចំសំណុំលិខិតស្នើសុំប័ណ្ណ និងសៀវភៅការងាររបស់ជនបរទេស បញ្ជូនមកក្រសួង ពិនិត្យ សម្រេច
- គ្រប់គ្រងការប្រើប្រាស់កំលាំងពលករកម្ពុជាទាំងក្នុង និងក្រៅប្រទេស និងសហការក្នុងការគ្រប់គ្រងជនបរទេស ដែលចូលមកប្រកបមុខរបរនៅក្នុងប្រទេស
- ត្រួតពិនិត្យ តាមដានការអនុវត្តន៍ច្បាប់ស្តីពីការងារ និងបទប្បញ្ញត្តិពាក់ព័ន្ធទៅនឹងបទដ្ឋានការងារលក្ខខណ្ឌការងារ សំដៅធានាកែលំអអនាម័យ និងសន្តិសុខការងារ សុខភាពកម្មករនិយោជិត និងលក្ខខណ្ឌ ធ្វើការងារនៅក្នុងសហគ្រាស គ្រឹះស្ថានដែលស្ថិតនៅក្នុង ខេត្ត ក្រុង
- សហការអនុវត្ត តាមដានពិនិត្យ ការអនុវត្តន៍នយោបាយរបស់រាជរដ្ឋាភិបាល ផែនការជាតិ អនុសញ្ញា អន្តរជាតិ គម្រោងកម្មវិធីនានា ដែលពាក់ព័ន្ធអនុសញ្ញា និងសន្ធិសញ្ញាអន្តរជាតិ ដែលពាក់ព័ន្ធនឹង ការងារកុមារ
- ធ្វើការអប់រំ ផ្សព្វផ្សាយ ចំពោះនិយោជក និងកម្មករនិយោជិត ដើម្បីគោរពបទប្បញ្ញត្តិច្បាប់ ស្តីពីការងារ
- ធ្វើការបូកសរុបរបាយការណ៍ជាប្រចាំ និងជាកាលិករបស់ខ្លួន ដើម្បីធ្វើជូនក្រសួង
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលក្រសួងប្រគល់ជូន ។

## គ. ទិសិយបណ្តុះបណ្តាលវិជ្ជាជីវៈ

- គ្រប់គ្រងមជ្ឈមណ្ឌល និងសាលាអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដែលស្ថិតនៅក្រោមឱវាទ ផ្ទាល់របស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត ក្រុង រៀបចំកម្មវិធី និងបញ្ចូលសិក្ខាកាមចូលរួម វគ្គបណ្តុះបណ្តាលជំនាញនានា
- សហការជាមួយសហគ្រាស គ្រឹះស្ថាន ដែលបោះទីតាំងនៅក្នុងមូលដ្ឋាន ខេត្ត ក្រុង ជំរុញឱ្យអនុវត្តកាតព្វកិច្ចហ្វឹកហ្វឺនមុខជំនាញដល់កូនជាង ទៅតាមច្បាប់ស្តីពីការងារ
- សហការចាត់ចែងធ្វើតេស្ត អំពីគុំរិតវិជ្ជាជីវៈគ្រប់ប្រភេទមុខរបរ និងធ្វើការផ្តល់ប័ណ្ណទទួលស្គាល់វិជ្ជាជីវៈ ដោយយោងទៅតាមលទ្ធផលនៃការធ្វើតេស្ត
- ប្រមូលកសាងស្ថិតិការងារ និងព័ត៌មានទីផ្សារការងារ
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលក្រសួងប្រគល់ជូន ។

**ប្រការ ៣** : មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្ត ក្រុង ដឹកនាំដោយប្រធានមន្ទីរមួយរូប និងមានអនុប្រធានមន្ទីរមួយចំនួនជាជំនួយការតាមការចាំបាច់ ។

មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្ត ក្រុង មានការិយាល័យ អង្គភាពចំណុះដូចខាងក្រោម :

១- ការិយាល័យ រដ្ឋបាល បុគ្គលិក និងផែនការ

២- ការិយាល័យ ហិរញ្ញវត្ថុ

៣- ការិយាល័យ ការងារ

៤- ការិយាល័យ បណ្តុះបណ្តាលវិជ្ជាជីវៈ

៥- មជ្ឈមណ្ឌល បណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្ត ក្រុង

៦- ការិយាល័យ ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្រុក ខណ្ឌ នៃមន្ទីរ ខេត្ត ក្រុង

ការិយាល័យ និងអង្គភាពនីមួយៗ ដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់ ។ តួនាទី ភារកិច្ចរបស់អង្គភាពនីមួយៗ មានដូចខាងក្រោម :

### ក. ការិយាល័យ រដ្ឋបាល បុគ្គលិក និង ផែនការ

ជាជំនួយការរបស់មន្ទីរ លើការគ្រប់គ្រង និងសម្របសម្រួល :

- លិខិត ចេញ ចូល ការបញ្ជូនលិខិតផ្ទៃក្នុង និងទៅក្រៅអង្គភាព
- ការគ្រប់គ្រង និងតម្កល់ឯកសារ
- ការតាក់តែងរៀបចំអត្ថបទលិខិតរដ្ឋបាលផ្សេងៗ និងឯកសារសហប្រតិបត្តិការ
- ពិធីការ អនាម័យ សន្តិសុខ
- បូកសរុបរបាយការណ៍ប្រចាំសប្តាហ៍ ខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ
- ការងារគ្រប់គ្រងមន្ត្រីរាជការ
- ភារកិច្ចផ្សេងៗទៀតដែលមន្ទីរប្រគល់ជូន ។

### ខ. ការិយាល័យ ហិរញ្ញវត្ថុ

ជាជំនួយការរបស់មន្ទីរ ទទួលបន្ទុក :

- ការងារគ្រប់គ្រងបញ្ជីសារពើភ័ណ្ឌ សម្ភារៈ បរិក្ខារ ចលនទ្រព្យ អចលនទ្រព្យ នៃអង្គភាពក្រោមឱវាទមន្ទីរ
- បៀវត្សមន្ត្រីរាជការ
- រៀបចំគម្រោងថវិកាប្រចាំឆ្នាំ
- ការប្រមូលចំណូលបង់ចូលថវិការដ្ឋស្របតាមច្បាប់ហិរញ្ញវត្ថុកំណត់
- សម្របសម្រួលការស្នើសុំរបបគោលនយោបាយដែលការិយាល័យជំនាញលើកឡើង ដាក់ជូនថ្នាក់ដឹកនាំមន្ទីរសម្រេច

- សហការជាមួយការិយាល័យពាក់ព័ន្ធ លើកគម្រោងថែទាំ ជួសជុលអាគារ មធ្យោបាយដឹកជញ្ជូន និងសម្ភារៈប្រើប្រាស់ផ្សេងៗ
- គ្រប់គ្រងហិរញ្ញវត្ថុ ដោយអនុវត្តតាមបែបបទគ្រប់គ្រងរបស់ក្រសួង
- ធ្វើរបាយការណ៍ពីការប្រើប្រាស់ថវិកាតាមការកំណត់
- ភារកិច្ចផ្សេងៗដែលមន្ទីរប្រគល់ជូន ។

## គ. ការិយាល័យ ការងារ

ជាជំនួយការរបស់មន្ទីរ ទទួលបន្ទុក ក្នុងការត្រួតពិនិត្យ ការអនុវត្តន៍ច្បាប់ស្តីពីការងារ តាមសហគ្រាស គ្រឹះស្ថាន ដែលស្ថិតនៅក្នុងតំបន់គ្រប់គ្រងរដ្ឋបាល ខេត្ត ក្រុង ជាអាទិ៍ :

- ធ្វើអធិការកិច្ចការងារ ដើម្បីត្រួតពិនិត្យល័ក្ខខ័ណ្ឌ និងសន្តិសុខការងាររបស់កម្មករនិយោជិត តាមសហគ្រាស គ្រឹះស្ថាន
- ដោះស្រាយវិវាទការងារទៅតាមច្បាប់ការងារ លិខិតបទដ្ឋានណែនាំរបស់ក្រសួង និងនីតិវិធីដែលបានកំណត់
- ត្រួតពិនិត្យសុវត្ថិភាព និងអនាម័យការងារ តាមសហគ្រាស គ្រឹះស្ថាន ដោយអនុវត្តតាមគោលការណ៍ណែនាំរបស់នាយកដ្ឋានពេទ្យការងារ និងនាយកដ្ឋានសន្តិសុខសង្គម
- ធ្វើការត្រួតពិនិត្យពលករកុមារ និងសហការជាមួយនាយកដ្ឋានការងារកុមារ ទៅលើផែនការជាតិ លុបបំបាត់ពលកម្មកុមារ ស្របតាមអនុសញ្ញាអន្តរជាតិ
- ធ្វើប័ណ្ណការងារ និងសៀវភៅការងារកម្មករនិយោជិតខ្មែរ
- ទទួល និងរៀបចំសំណុំលិខិតស្នើសុំធ្វើ ឬពន្យារសុពលភាពប័ណ្ណការងារ និងសៀវភៅការងារជនបរទេស រួចបញ្ជូនមកក្រសួងពិនិត្យសម្រេច
- សហការសម្របសម្រួល ពិនិត្យ និងតាមដានសកម្មភាពក្រុមហ៊ុនដែលក្រសួងបានផ្តល់អាជ្ញាប័ណ្ណឱ្យជ្រើសរើសពលករទៅធ្វើការក្រៅប្រទេស
- ជួយសម្របសម្រួលជួយស្វែងរកការងារធ្វើជូនប្រជាពលរដ្ឋបានដាក់ពាក្យសុំរកការងារធ្វើទាំងក្នុង និងក្រៅប្រទេស
- ភារកិច្ចផ្សេងៗទៀតដែលមន្ទីរប្រគល់ជូន ។

## ឃ. ការិយាល័យ បណ្តុះបណ្តាលវិជ្ជាជីវៈ

ជាជំនួយការរបស់មន្ទីរ ទទួលបន្ទុក :

- សហការជាមួយមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់មន្ទីរខេត្តក្រុង
- សហការជាមួយ សហគ្រាស គ្រឹះស្ថាន ដើម្បីពង្រឹងលើគុណភាពបណ្តុះបណ្តាលវិជ្ជាជីវៈ

- រៀបចំផែនការបណ្តុះបណ្តាលវិជ្ជាជីវៈដល់ជនដែលគ្មានការងារធ្វើ និងគ្មានជំនាញ និងការបណ្តុះបណ្តាលពិសេស
- សហការជាមួយអង្គការអន្តរជាតិ អង្គការមិនមែនរាជរដ្ឋាភិបាលក្នុងការអនុវត្តន៍ខ្លឹមសារ ពិធីសារ ឬកិច្ចព្រមព្រៀងស្តីពីការងារបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដែលបានចុះជាមួយក្រសួង ឬខេត្ត ក្រុង
- កសាងស្ថិតិការងារ និងព័ត៌មានទីផ្សារការងារ ដោយអនុវត្តតាមគោលការណ៍ណែនាំរបស់នាយកដ្ឋានព័ត៌មានទីផ្សារការងារ
- សិក្សាស្រាវជ្រាវមុខរបរជាអាទិភាពតាមតម្រូវការទីផ្សារការងារក្នុងមូលដ្ឋាន ខេត្ត ក្រុង
- ផ្សព្វផ្សាយព័ត៌មានទីផ្សារការងារជាសាធារណៈ
- សហការរៀបចំការធ្វើតេស្តសមត្ថភាពជំនាញ និងចេញប័ណ្ណទទួលស្គាល់មុខជំនាញ
- សហការជាមួយសហគ្រាស គ្រឹះស្ថាន ដើម្បីជំរុញកាតព្វកិច្ចហ្វឹកហ្វឺនកូនជាង តាមគោលការណ៍ណែនាំ
- ភារកិច្ចផ្សេងៗទៀតដែលមន្ទីរប្រគល់ជូន ។

## ខ. មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ

ជាជំនួយការរបស់មន្ទីរ ទទួលបន្ទុក :

- រៀបចំកំណត់កម្មវិធី មធ្យោបាយបណ្តុះបណ្តាលវិជ្ជាជីវៈ សំរាប់វគ្គបណ្តុះបណ្តាល
- រៀបចំបទបញ្ជាផ្ទៃក្នុងរបស់មជ្ឈមណ្ឌល
- រៀបចំការវាយតម្លៃ ប្រឡងបញ្ចប់វគ្គ
- រៀបចំ និងផ្តល់វិញ្ញាបនប័ត្របញ្ជាក់ការសិក្សា
- រិះរកមធ្យោបាយ ដើម្បីបណ្តុះបណ្តាលស្របតាមសេចក្តីត្រូវការនៃទីផ្សារការងារ ពិសេសសហការជាមួយ សហគ្រាស គ្រឹះស្ថាន
- សហការជាមួយអង្គការនានា ដើម្បីពង្រឹង និងពង្រីកមជ្ឈមណ្ឌល និងការបណ្តុះបណ្តាលវិជ្ជាជីវៈ
- ធ្វើការប៉ាន់ប្រមាណ និងលើកគម្រោងតម្រូវការបណ្តុះបណ្តាលវិជ្ជាជីវៈ
- ធ្វើរបាយការណ៍ ស្តីពីសកម្មភាពបណ្តុះបណ្តាលជូនក្រសួងតាមរយៈមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត ក្រុង
- អនុវត្តគោលការណ៍ណែនាំ សេចក្តីប្រកាស សារាចរណែនាំរបស់អភិបាល ខេត្ត ក្រុង និងក្រសួង
- អនុវត្តការធ្វើតេស្តបញ្ជាក់សមត្ថភាព និងបញ្ជាក់វិញ្ញាបនប័ត្រវិជ្ជាជីវៈ
- ទំនាក់ទំនងកិច្ចការផ្ទៃករដ្ឋបាលជាមួយ នឹងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- សហការរវាងមជ្ឈមណ្ឌលបណ្តុះបណ្តាល ខេត្ត ក្រុង ដទៃដើម្បីផ្លាស់ប្តូរបទពិសោធន៍ទៅវិញ ទៅមកសំដៅអភិវឌ្ឍន៍ការងារឱ្យមានការរីកចំរើន
- ភារកិច្ចផ្សេងៗទៀតដែលមន្ទីរប្រគល់ជូន ។

**ច. ការិយាល័យ ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្រុក ខណ្ឌ**

ជាជំនួយការរបស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈនៅក្នុងមូលដ្ឋានស្រុក ខណ្ឌ ទទួលបន្ទុកអនុវត្ត និងសម្របសម្រួលសកម្មភាពនានារបស់ក្រសួង និងតាមបទបញ្ជារបស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត ក្រុង។

**ប្រការ ៤ :** ការរៀបចំ និងការប្រព្រឹត្តទៅរបស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានីភ្នំពេញ នឹងត្រូវកំណត់ដោយប្រកាសមួយដោយឡែក ។

**ប្រការ ៥ :** ប្រកាស និងបទប្បញ្ញត្តិទាំងឡាយ ដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៦ :** ប្រកាសនេះ មានប្រសិទ្ធភាព អនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

*រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០០៦*

**រដ្ឋមន្ត្រី**

ញ៉ែប_ប៊ុនជិន

**ចម្លងជូន :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- គ្រប់សាលា ខេត្ត ក្រុង

  " ដើម្បីជូនជ្រាប "
- គ្រប់អង្គភាពក្រោមឱវាទក្រសួង

  " ដើម្បីអនុវត្ត "
- ឯកសារ-កាលប្បវត្តិ

# អង្គការលេខរបស់មន្ទីរការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ខេត្ត ក្រុង

*ឧបសម្ព័ន្ធនៃប្រកាសលេខ ០៥២ កកបវ/ប្រក ចុះថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០០៦*



**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការពារជាតិ**
លេខ : ០៦៤ / ០៦

រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០០៦

# ប្រកាស
## ស្តីពី
## ការបង្កើតក្រុមប្រឹក្សាកីឡាកងយោធពលខេមរភូមិន្ទ

## សហរដ្ឋមន្ត្រី ក្រសួងការពារជាតិ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ /នស /៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកត/០១៩៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៥ ចុះថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិន នៃកងយោធពលខេមរភូមិន្ទ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ ២០០១ ស្តីពីការកែសំរួលតួនាទី ភារៈកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់ អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ១៤ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៣១ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការកែសំរួលរចនាសម្ព័ន្ធ និងប្តូរ ឈ្មោះខុទ្ទកាល័យក្រសួងការពារជាតិ មកជាអគ្គលេខាធិការដ្ឋាន ក្រសួងការពារជាតិ
- យោងលិខិត លេខ ១៧៧៦/ស.ជ.ណ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០០៥ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- តាមសំណើរបស់អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ

## សម្រេច

**ប្រការ ១** : បង្កើតក្រុមប្រឹក្សាកីឡាមួយមានឈ្មោះថា **ក្រុមប្រឹក្សាកីឡាកងយោធពលខេមរភូមិន្ទ** ដែលមានអក្សរកាត់

ជាភាសាខ្មែរ ក.ម.ក.ខ.ភ.ម ជាអក្សរឡាតាំង **C.S.R.C.A.F.** ( Council Sport of Royal Cambodian Armed Forces ) ។

**ប្រការ ២** : សមាសភាព នៃក្រុមប្រឹក្សាអង្គការកីឡាកងយោធពលខេមរភូមិន្ទ រួមមាន :

| | | | |
|---|---|---|---|
| ១-ឯកឧត្តម ឧត្តមសេនីយ៍ឯក | **ម៉ឹង សំផន** | រដ្ឋលេខាធិការក្រសួងការពារជាតិ | ជាប្រធាន |
| ២-ឯកឧត្តម ឧត្តមសេនីយ៍ឯក | **ជា សារ៉ែន** | មេបញ្ជាការរង និងជានាយសេនាធិការកងទ័ពជើងគោក | ជាអនុប្រធាន |
| ៣-ឯកឧត្តម ឧត្តមសេនីយ៍ឯក | **ឥត សារ៉ាត់** | នាយរងសេនាធិការចំរុះ និងជានាយកទីចាត់ការហ្វឹកហ្វឺន | ជាអនុប្រធាន |
| ៤-ឯកឧត្តម ឧត្តមសេនីយ៍ត្រី | **តែម ម៉ឹន** | នាយករងទីចាត់ការហ្វឹកហ្វឺន និងជាប្រធានមជ្ឈមណ្ឌលកីឡាកងយោធពលខេមរភូមិន្ទ | ជាសមាជិកអចិន្ត្រៃយ៍ |
| ៥-ឯកឧត្តម ឧត្តមសេនីយ៍ឯក | **សំ វណ្ណថន** | អគ្គលេខាធិការ ក្រសួងការពារជាតិ | ជាសមាជិក |
| ៦-ឯកឧត្តម ឧត្តមសេនីយ៍ឯក | **ស៊ុំ សំណាង** | អគ្គនាយក អគ្គនាយកដ្ឋាន ភស្តុភារ-ហិរញ្ញវត្ថុ | ជាសមាជិក |
| ៧-ឯកឧត្តម ឧត្តមសេនីយ៍ឯក | **ចៅ តិរុណ** | អគ្គនាយក អគ្គនាយកដ្ឋាន សម្ភារៈបច្ចេកទេស | ជាសមាជិក |
| ៨- ឯកឧត្តម ឧត្តមសេនីយ៍ឯក | **មាស សារឿន** | អគ្គនាយក អគ្គនាយកដ្ឋានយោធសេវា | ជាសមាជិក |
| ៩- ឯកឧត្តម ឧត្តមសេនីយ៍ឯក | **ស៊ឹង សំណាង** | មេបញ្ជាការកងទ័ពជើងអាកាស | ជាសមាជិក |
| ១០-ឯកឧត្តម ឧត្តមនាវីឯក | **អ៊ឹង សំខាន់** | មេបញ្ជាការកងទ័ពជើងទឹក | ជាសមាជិក |
| ១១-ឯកឧត្តមឧត្តមសេនីយ៍ឯក | **សៅ សុខា** | មេបញ្ជាការ កងរាជអាវុធហត្ថលើផ្ទៃប្រទេស | ជាសមាជិក |
| ១២-ឯកឧត្តមឧត្តមសេនីយ៍ឯក | **មាស សំអុល** | នាយក នាយកដ្ឋានបុគ្គលិក | ជាសមាជិក |
| ១៣-ឯកឧត្តមឧត្តមសេនីយ៍ឯក | **ជាំ ឫទ្ធី** | នាយរងសេនាធិការចំរុះនិងជានាយកទីចាត់ការបុគ្គលិក | ជាសមាជិក |

**ប្រការ ៣** : ក្រុមប្រឹក្សាកីឡាកងយោធពលខេមរភូមិន្ទ មានភារកិច្ចដូចខាងក្រោម :

- គ្រប់គ្រង និងដឹកនាំ ដល់បណ្តាសមាគមន៍ និងក្លឹបកីឡានានា ក្នុងកងយោធពលខេមរភូមិន្ទ ។
- រៀបចំក្រុមកីឡាកងយោធពលខេមរភូមិន្ទ ចូលរួមប្រកួតជាលក្ខណៈ ជាតិ-អន្តរជាតិ ។
- សហការជាមួយស្ថាប័នកីឡាជាតិ និងស្ថាប័នកីឡាអន្តរជាតិ ផ្លាស់ប្តូរជកបទពិសោធន៍ បណ្តុះបណ្តាល និងស្វែងរកប្រភពក្នុងការទ្រទ្រង់ កសាងកីឡាកងយោធពលខេមរភូមិន្ទ ។
- មានសិទ្ធិចូលរួមប្រជុំរាល់វេទិកាកីឡាទាំងអស់ ដែលពាក់ព័ន្ធជាមួយកងយោធពលខេមរភូមិន្ទ ។
- ក្រុមប្រឹក្សាកីឡាកងយោធពលខេមរភូមិន្ទមានសិទ្ធិតែងតាំងគណៈកម្មការប្រតិបត្តិ និងអគ្គលេខាធិការដើម្បីដំណើរការរាល់ភារកិច្ចរបស់ខ្លួន ។
- មានសិទ្ធិបង្កើតគណៈកម្មការក្នុងពេលដំណើរការប្រកួត និងពិធីនានា របស់កីឡាកងយោធពលខេមរភូមិន្ទ ព្រមទាំងដោះស្រាយនូវរាល់ភាពអសកម្មទាំងឡាយ ។

- ក្រុមប្រឹក្សានេះមានសិទ្ធិប្រើប្រាស់ត្រា និងរូបសញ្ញារបស់ខ្លួនសំរាប់ដំណើរការលើកិច្ចការរដ្ឋបាលនានា ។

**ប្រការ ៤ :** អគ្គមេបញ្ជាការ ខភម អគ្គលេខាធិការ ក្រសួងការពារជាតិ អគ្គនាយក អគ្គនាយកដ្ឋាន នាយក ទីចាត់ការ ហ្វឹកហ្វឺន នាយក នាយកដ្ឋាន ប្រធាន ស្ថាប័ន មេបញ្ជាការ កងឯកភាពដែលមានការពាក់ព័ន្ធ និងសមាសភាពក្នុងប្រការ២ ត្រូវអនុវត្តតាមសេចក្តីប្រកាសនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយឧ.ផ្កាយមាសេ៥ ទៀ-បាញ់ នាយឧ.ផ្កាយមាស៤.ញឹក-ប៊ុនឆៃ

**ចម្លងជូន**

- ថ្នាក់ដឹកនាំក្រសួងការពារជាតិ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងអប់រំយុវជន និងកីឡា
- គណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា
- ខុទ្ទកាល័យ សម្តេច នាយករដ្ឋមន្ត្រី
- ទីប្រឹក្សាក្រសួងការពារជាតិ
- ខុទ្ទកាល័យ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ទៀ បាញ់
- ខុទ្ទកាល័យ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ញឹក ប៊ុនឆៃ

"ដើម្បីជូនជ្រាប"

- អគ្គបញ្ជាការដ្ឋាន .ខភម
- ស្ថាប័នកីឡាជាតិ
- ដូចប្រការ ៤

(ដើម្បីជ្រាប និងសហការអនុវត្ត)

- ឯកសារ- កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

លេខ ០៥ សាសរ

ថ្ងៃទី 24 ខែ 3 ឆ្នាំ 2006

# សេចក្តីសំរេច

## ស្តីពី

## ការកំណត់បរិបថនៃការពិនិត្យ និងសំរេចលើពាក្យសុំលិខិតអនុញ្ញាតសាងសង់

★★★★★★

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ផ្អែកតាមអនុក្រឹត្យលេខ ៨៦ អនក្រ/បក ចុះថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីលិខិតអនុញ្ញាតសាងសង់
- ផ្អែកតាមអនុក្រឹត្យលេខ ៦២ អនក្រ/បក ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- យោងប្រកាសលេខ ៦៤ ប្រក/ដនស ចុះថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ១៩៩៩ ស្តីពីតួនាទីភារកិច្ច និងរចនាសម្ព័ន្ធរបស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្ត ក្រុង និងតួនាទីភារកិច្ចរបស់បណ្តាការិយាល័យក្រោមឱវាទ
- យោងលិខិតលេខ ៧៧៥ ដនស/អដន/០៤ ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីកំណែទំរង់សេវាត្រួតពិនិត្យពាក្យសុំ និងផ្តល់លិខិតអនុញ្ញាតសាងសង់
- យោងលិខិតលេខ ១០៨ សជណ ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០០៦ របស់ក្រសួងមហាផ្ទៃ ។

## សំរេច

**ប្រការ ១** : កំណត់បរិបថនៃការពិនិត្យ និងសំរេចលើពាក្យសុំលិខិតអនុញ្ញាតសាងសង់ ដូចខាងក្រោម ÷

ក- បរិបថនៃការពិនិត្យ និងសំរេចលើពាក្យសុំលិខិតអនុញ្ញាតសាងសង់ ដែលជាសមត្ថកិច្ចរបស់សាលាខេត្ត ក្រុង

សំណុំឯកសារនៃពាក្យសុំលិខិតអនុញ្ញាតសាងសង់ ត្រូវធ្វើតាមរយៈអាជ្ញាធរមូលដ្ឋានឃុំ សង្កាត់ ស្រុក ខណ្ឌ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្ត ក្រុង ឬអង្គភាពពាក់ព័ន្ធក្នុង

ករណីចាំបាច់ ហើយបញ្ជូនសំណុំឯកសារនៃពាក្យសុំលិខិតអនុញ្ញាតសាងសង់ ដោយមានភ្ជាប់នូវយោបល់ និងមូលវិចាររបស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ទៅសាលាខេត្ត ក្រុង ដើម្បីពិនិត្យ និងសំរេច ក្នុងរយៈពេលយ៉ាងយូរ ៣០ (សាមសិប) ថ្ងៃនៃថ្ងៃធ្វើការ ដោយកំណត់ដូចខាងក្រោម ÷

- ម្ចាស់សំណើត្រូវដាក់ពាក្យសុំលិខិតអនុញ្ញាតសាងសង់ នៅការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល ស្រុក ខណ្ឌ ដោយឡែកចំពោះក្រុងភ្នំពេញ ម្ចាស់សំណើត្រូវដាក់ពាក្យសុំ នៅការិយាល័យរដ្ឋបាលនៃមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ។ ការពិនិត្យ និងសំរេចលើពាក្យសុំលិខិតអនុញ្ញាតសាងសង់ នៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្ត ក្រុង រយៈពេលយ៉ាងយូរ ២៥ (ម្ភៃប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ គិតរួមទាំងការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល ស្រុក ខណ្ឌ និងនៅសាលាខេត្ត ក្រុង រយៈពេលយ៉ាងយូរ ៥ (ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ សរុបទាំងអស់ ៣០ (សាមសិប) ថ្ងៃនៃថ្ងៃធ្វើការ (ដូចមានចែងក្នុងឧបសម្ព័ន្ធ I)
- ម្ចាស់សំណើត្រូវដាក់ពាក្យសុំលិខិតអនុញ្ញាតបើកការដ្ឋាន បិទការដ្ឋាន ឬវិញ្ញាបនប័ត្របញ្ជាក់ភាពត្រឹមត្រូវ នៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត ក្រុង ។ ការពិនិត្យ និងសំរេចលើពាក្យសុំលិខិតអនុញ្ញាតបើកការដ្ឋាន នៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្ត ក្រុង រយៈពេលយ៉ាងយូរ ៦ (ប្រាំមួយ) ថ្ងៃនៃថ្ងៃធ្វើការ (ដូចមានចែងក្នុងឧបសម្ព័ន្ធ II សន្លឹក ៣)
- ការពិនិត្យ និងសំរេចលើពាក្យសុំលិខិតបិទការដ្ឋាន ឬវិញ្ញាបនប័ត្របញ្ជាក់ភាពត្រឹមត្រូវ នៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្ត ក្រុង រយៈពេលយ៉ាងយូរ ៦ (ប្រាំមួយ) ថ្ងៃនៃថ្ងៃធ្វើការ (ដូចមានចែងក្នុងឧបសម្ព័ន្ធ II សន្លឹក ៤) ។

ខ-បរិបថនៃការពិនិត្យ និងសំរេចលើពាក្យសុំលិខិតអនុញ្ញាតសាងសង់ ដែលជាសមត្ថកិច្ចរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

សាលាខេត្ត ក្រុង ត្រូវបញ្ជូនសំណុំឯកសារនៃពាក្យសុំលិខិតអនុញ្ញាតសាងសង់ ដោយភ្ជាប់ជាមួយនូវលិខិតដែលជាយោបល់របស់សាលាខេត្ត ក្រុង មកក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីពិនិត្យ និងសំរេចក្នុងរយៈពេលយ៉ាងយូរ ១៥ (ដប់ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ ដោយមិនគិតពីរយៈពេល ៣០ (សាមសិប) ថ្ងៃនៃថ្ងៃធ្វើការរបស់សមត្ថកិច្ចសាលាខេត្ត ក្រុង ដោយកំណត់ដូចខាងក្រោម ÷

- ការពិនិត្យ និងសំរេចលើពាក្យសុំលិខិតអនុញ្ញាតសាងសង់ នៅអគ្គនាយកដ្ឋានរដ្ឋបាល រយៈពេលយ៉ាងយូរ ១ (មួយ) ថ្ងៃនៃថ្ងៃធ្វើការ (ដូចមានចែងក្នុងឧបសម្ព័ន្ធ I សន្លឹក ៦)

- ការពិនិត្យ និងសំរេចលើពាក្យសុំលិខិតអនុញ្ញាតសាងសង់ នៅអគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម រយៈពេលយ៉ាងយូរ ១២ (ដប់ពីរ) ថ្ងៃនៃថ្ងៃធ្វើការ (ដូចមានចែងក្នុងឧបសម្ព័ន្ធ I សន្លឹក ៦)
- ការពិនិត្យ និងសំរេចលើពាក្យសុំលិខិតអនុញ្ញាតសាងសង់ នៅអគ្គនាយកដ្ឋានសំណង់ រយៈពេលយ៉ាងយូរ ១០ (ដប់) ថ្ងៃនៃថ្ងៃធ្វើការ ស្របពេលនៃការពិនិត្យរបស់អគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម (ដូចមានចែងក្នុងឧបសម្ព័ន្ធ I សន្លឹក ៧)
- ការពិនិត្យ និងសំរេចលើពាក្យសុំលិខិតអនុញ្ញាតសាងសង់ នៅខុទ្ទកាល័យទេសរដ្ឋមន្ត្រី រយៈពេលយ៉ាងយូរ ២ (ពីរ) ថ្ងៃនៃថ្ងៃធ្វើការ (ដូចមានចែងក្នុងឧបសម្ព័ន្ធ I សន្លឹក ១)
- ម្ចាស់សំណើត្រូវដាក់ពាក្យសុំលិខិតអនុញ្ញាតបើកការដ្ឋាន បិទការដ្ឋាន ឬវិញ្ញាបនប័ត្របញ្ជាក់ភាពត្រឹមត្រូវ នៅនាយកដ្ឋានសំណង់នៃអគ្គនាយកដ្ឋានសំណង់ ។ ការពិនិត្យ និងសំរេចលើពាក្យសុំលិខិតអនុញ្ញាតបើកការដ្ឋាន នៅអគ្គនាយកដ្ឋានសំណង់ រយៈពេលយ៉ាងយូរ ៨ (ប្រាំបី) ថ្ងៃនៃថ្ងៃធ្វើការ (ដូចមានចែងក្នុងឧបសម្ព័ន្ធ II សន្លឹក១)
- ការពិនិត្យ និងសំរេចលើពាក្យសុំលិខិតបិទការដ្ឋាន ឬវិញ្ញាបនប័ត្របញ្ជាក់ភាពត្រឹមត្រូវ នៅអគ្គនាយកដ្ឋានសំណង់ រយៈពេលយ៉ាងយូរ ៦ (ប្រាំមួយ) ថ្ងៃនៃថ្ងៃធ្វើការ (ដូចមានចែងក្នុងឧបសម្ព័ន្ធ II សន្លឹក ២) ។

គ- និតិវិធីនៃការពិនិត្យ និងសំរេចលើពាក្យសុំលិខិតអនុញ្ញាតសាងសង់ ត្រូវបានកំណត់ដូចខាងក្រោម

- រយៈពេលពិនិត្យ និងសំរេចលើពាក្យសុំលិខិតអនុញ្ញាតសាងសង់ គិតចាប់ពីថ្ងៃដែលរាល់លិខិតស្នាមភ្ជាប់មកជាមួយនឹងពាក្យសុំលិខិតអនុញ្ញាតសាងសង់ បានបំពេញគ្រប់គ្រាន់ និងត្រឹមត្រូវ ហើយម្ចាស់សំណើទទួលបានបង្កាន់ដៃទទួលពាក្យសុំ
- ក្នុងករណីសំណុំឯកសារនៃពាក្យសុំមានលក្ខណៈខ្វះខាតឬខុសឆ្គង មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្ត ក្រុង ឬអគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម និងអគ្គនាយកដ្ឋានសំណង់ ត្រូវធ្វើសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរដល់អ្នកស្នើសុំឱ្យបំពេញបន្ថែម ឬកែតម្រូវ។ រយៈពេលពិនិត្យ និងសំរេចដែលជាសមត្ថកិច្ចសាលាខេត្ត ក្រុង ឬក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ លើការបំពេញបន្ថែម ឬកែតម្រូវលើសំណុំឯកសារនៃពាក្យសុំ ត្រូវគិតជាថ្មី ចាប់ពីថ្ងៃដាក់ឡើងវិញនូវពាក្យសុំលិខិតអនុញ្ញាតសាងសង់
- ក្នុងករណីការពិនិត្យ និងសំរេចលើសំណុំឯកសារនៃពាក្យសុំលិខិតអនុញ្ញាតសាងសង់ មានការអូសបន្លាយពេលវេលាលើសពីការកំណត់ ដោយគ្មានមូលហេតុសមស្រប មន្ត្រីពាក់ព័ន្ធត្រូវទទួលខុសត្រូវចំពោះម្ចាស់សំណើ និងច្បាប់ជាធរមាន។

**ប្រការ ២:** នាយកខុទ្ទកាល័យ អគ្គនាយកគ្រប់អគ្គនាយកដ្ឋាន គ្រប់ប្រធាននាយកដ្ឋានពាក់ព័ន្ធ អស់លោក និងលោកស្រី ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី គ្រប់ខេត្ត ក្រុង ត្រូវអនុវត្តសេចក្តីសំរេចនេះ តាមភារៈកិច្ចរៀង១ខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ភ្នំពេញ, ថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០០៦

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**អ៊ឹម ឈុនលឹម**

**កន្លែងទទួល**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- គ្រប់សាលាខេត្ត ក្រុង (ដើម្បីសហការអនុវត្ត)
- ដូចប្រការ ២ (ដើម្បីអនុវត្ត)
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធ ।

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

អគ្គនាយកដ្ឋានសំណង់

នាយកដ្ឋានសិក្សាគំរោងប្លង់

# បរិបថនៃការពិនិត្យ និងសំរេចលើពាក្យសុំ

# លិខិតអនុញ្ញាតសាងសង់

**សន្លឹក ១**

## បរិបថនៃការពិនិត្យ និងសំរេចលើពាក្យសុំលិខិតអនុញ្ញាតសាងសង់ ដែលជាសមត្ថកិច្ចរបស់ សាលាខេត្ត ក្រុង និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់




កំណត់សំគាល់:

-សន្លឹក ៨ ត្រូវរៀបចំដោយសាលាខេត្ត ក្រុង

**សន្លឹក ២**

## បរិបថនៃការពិនិត្យ និងសំរេចលើពាក្យសុំលិខិតអនុញ្ញាតសាងសង់ នៅក្នុងមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានីភ្នំពេញ



**សន្លឹក ៣**

## បរិបថនៃការពិនិត្យ និងសំរេចលើពាក្យសុំលិខិតអនុញ្ញាតសាងសង់ នៅក្នុងមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្ត ក្រុង




កំណត់សំគាល់:

- អាស្រ័យទៅតាមសំណុមពរការងារបច្ចេកទេសជាក់ស្តែង ការិយាល័យ សុរិយោដី និង ភូមិសាស្ត្រទឹងត្រូវកាត់រោរបរអនុវត្តការងារតាមអេខជំនាញ ។

សន្លឹក ៤

# បរិបថនៃការពិនិត្យ និងសំរេចលើពាក្យសុំលិខិតអនុញ្ញាតសាងសង់ នៅក្នុងមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តសៀមរាប




**កំណត់សំគាល់:**

